ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌ
លេខ: ៦០០ "គ១ក្រ១០"
ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២១
-សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៧៩៩៨
ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០២០
-សំណុំរឿងស៊ើបសួរ
លេខ: ៥៨០៣
ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២០
-សំណុំរឿងជំនុំជម្រះ
លេខ: ២០០៧
ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២១

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០២១ វេលាម៉ោង ០២:០០ នាទីរសៀល នៅសាលសវនាការទី ៣ ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា។
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា។
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា។

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ។

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

មេធាវីការពារឱ្យជនជាប់ចោទ

-មេធាវី [redacted]
-មេធាវី [redacted]

ដើម្បីជំនុំជម្រះលើ សំណុំរឿងព្រហ្មទណ្ឌលេខ ៧៩៩៨ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០២០ ដែលមានជនជាប់ចោទដូចខាងក្រោម៖

១-ឈ្មោះ [redacted] សំណាង ភេទប្រុស ឆ្នាំកំណើត២៣-០២-២០០៤ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] ក្រុងភ្នំពេញ មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅបន្ទប់ជួល ផ្លូវបេតុង ភូមិកោះនរា សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] វុទ្ធី (រ) ម្តាយឈ្មោះ [redacted] គីមលី (រ) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ-ម២)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៣៣៤០ "ប"ដ.ឃ.ដ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០២០។

២-ឈ្មោះ [redacted] ពន្ធឺ ភេទប្រុស ឆ្នាំកំណើត១៨-០៦-២០០៦ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត [redacted] ខេត្តកណ្តាល មានទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅបន្ទប់ជួល ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុផល (រ) ម្តាយឈ្មោះ [redacted] ជាន់ឌី (រ) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ-ម២)

តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៣៣៣៩ "ប"ដ.ឃ.ដ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០២០។

Scanned with CamScanner

ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោស (ឆក់យកទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចមុខអាជាតមិន H.M.H ផ្លូវលេខ ១៣៥ កែងផ្លូវលេខ ៤៧៨ ស្ថិតនៅភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៣៥៣និងមាត្រា ៣៥៧នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនិច ភេទស្រី អាយុ៣១ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៥៦ ផ្លូវរថភ្លើង ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

អង្គហេតុនៃរឿងអាទិភាព

កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០ វេលាម៉ោង១៩និង៣០នាទី មានករណីលួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ) មួយកើតឡើង នៅចំណុចមុខអាជាតមិន HMH ផ្លូវលេខ ១៣៥ កែងផ្លូវលេខ ៤៧៨ ភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលបង្កឡើងដោយឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ពន្ធឺ បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃម៉ាក Iphone 6Plus ពណ៌ខ្មៅ ពីជនរងគ្រោះឈ្មោះ [redacted] ស្រីនិច រួចជិះគេចខ្លួន តែត្រូវសមត្ថកិច្ចជិះដេញតាម និងឃាត់ខ្លួនបានតែម្តង។

បានឃើញ របាយការណ៍សំយោគលេខ ០៩៥/២០ រ.ប.ក ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ១៣៨៩ អ.ឃ.ឋ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២០៤០ ដ.ដ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] សំណាង បានឆ្លើយថា៖ កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០ ឈ្មោះ [redacted] ពន្ធឺ ជិះម៉ូតូម៉ាក ហុងដា ឌ្រីម សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ ពាក់ផ្លាកលេខ ភ្នំពេញ 1FH-5171 មកឌុបខ្លួន។ ខ្លួននិងឈ្មោះ [redacted] ពន្ធឺ បាននាំគ្នាជិះដើរលេង ដោយឈ្មោះ [redacted] ពន្ធឺ ជាអ្នកបើកម៉ូតូ លុះជិះដល់ចំណុចមុខអាជាតមិន HMH ផ្លូវលេខ ១៣៥ កែងផ្លូវលេខ ៤៧៨ ម៉ោងប្រហែល១៩និង៣០នាទី ឈ្មោះ [redacted] ពន្ធឺ ជិះម៉ូតូទៅរែបជនរងគ្រោះ កំពុងនិយាយទូរស័ព្ទ ហើយខ្លួនក៏បានឆក់យកទូរស័ព្ទពីស្ត្រីដែលអង្គុយនិយាយទូរស័ព្ទលើម៉ូតូនោះ រួចជិះម៉ូតូគេចបានបន្តិច ក៏បុកនឹងម៉ូតូគេ បណ្តាលឱ្យដួលម៉ូតូ ទើបសមត្ថកិច្ចចាប់ឃាត់រូបខ្លួន និងឈ្មោះ [redacted] ពន្ធឺ បានតែម្តង។ ជនរងគ្រោះបានយកទូរស័ព្ទវិញរួចហើយ។ ម៉ូតូនេះ ជាម៉ូតូរបស់ឈ្មោះ [redacted] ពន្ធឺ។

- ជនជាប់ចោទឈ្មោះ [redacted] ពន្ធឺ បានឆ្លើយថា៖ កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០ ខ្លួនជិះម៉ូតូម៉ាក ហុងដា ឌ្រីម សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ ពាក់ផ្លាកលេខ ភ្នំពេញ 1FH-5171 របស់ខ្លួន ទៅឌុបឈ្មោះ [redacted] សំណាង ហើយបាននាំគ្នាជិះដើរលេង ដោយខ្លួនជាអ្នកបើកម៉ូតូ លុះជិះដល់ចំណុចមុខអាជាតមិន HMH ផ្លូវលេខ ១៣៥ កែងផ្លូវលេខ ៤៧៨ នៅម៉ោងប្រហែល១៩និង៣០នាទី ខ្លួនក៏ជិះម៉ូតូទៅរែបស្ត្រីកំពុងនិយាយទូរស័ព្ទ ហើយឈ្មោះ [redacted] សំណាង ក៏ឆក់យកទូរស័ព្ទពីស្ត្រី ដែលអង្គុយនិយាយទូរស័ព្ទលើម៉ូតូ រួចជិះម៉ូតូគេចបានបន្តិចក៏បុកជាមួយម៉ូតូគេបណ្តាលឱ្យដួល ទើបសមត្ថកិច្ចឃាត់រូបខ្លួន និងឈ្មោះ [redacted] សំណាង បានតែម្តង។

- ក្រឡាបញ្ជីអានកំណត់ហេតុរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីនិច នៅដំណាក់កាលសមត្ថកិច្ចថា៖ កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០ វេលាម៉ោងប្រហែល១៩និង៣០នាទី ខ្លួនបានជិះម៉ូតូចេញពីកន្លែងហាត់ប្រាណ ដែលមានទីតាំងនៅជិតកន្លែងកើតហេតុមកឈប់នៅមុខអាជាតមិន HMH ផ្លូវលេខ ១៣៥ កែងផ្លូវលេខ ៤៧៨ សង្កាត់ទួលទំពូងទី១ ខណ្ឌ

ចំការមន រាជធានីភ្នំពេញ រួចយកទូរស័ព្ទម៉ាក Iphone 6Plus ពណ៌ខ្មៅ ស៊ីមលេខ ០៨៨ ៣៨៨ ៩៣៥៤ មកចុចទាក់ទងរកមិត្តភក្តិ ពេលនោះមានជនល្មើស ០២នាក់ បានជិះម៉ូតូ០១គ្រឿង ម៉ាក សេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៥ ពាក់ផ្លាកលេខភ្នំពេញ 1FH-5171 ជិះមកអែបខាងឆ្វែងដៃខ្លួន ហើយជនល្មើសអង្គុយនៅខាងក្រោយ បានធ្វើសកម្មភាពឆក់ទូរស័ព្ទរបស់ខ្លួន ពេលឆក់បានក៏នាំគ្នាបើកម៉ូតូគេចខ្លួន រួចទៅបុកជាមួយឆ្វែងម៉ូតូគេដែលកំពុងធ្វើដំណើរតាមផ្លូវបណ្តាលឱ្យដួលម៉ូតូ ទើបសមត្ថកិច្ចនគរបាលកំពុងល្បាតក្បែរនោះ ឃើញក៏ឃាត់បានជនល្មើស រួមទាំងវត្ថុតាងទូរស័ព្ទដៃរបស់ខ្លួន នាំមកកាន់ប៉ុស្តិ៍នគរបាលតែម្តង។

សេចក្តីសន្និដ្ឋានឆ្លើយសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ស្តាប់ចម្លើយរបស់ជនជាប់ចោទ , ចម្លើយរបស់ដើមបណ្តឹង និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង រួចមក តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ពន្ធឺ ពិតជាបានប្រព្រឹត្តអំពើចោទប្រកាន់ច្រាកដមែន។ ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ទុកនៅដដែល។ សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

មេធាវីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ចម្លើយរបស់កូនក្តីខ្លួននាពេលសវនាការ យើញថា កូនក្តីខ្លួនបានធ្វើយសារភាពទទួលស្គាល់កំហុសរួចហើយ។ ដោយឡែក អំពើរបស់កូនក្តីខ្លួនដែលបានប្រព្រឹត្តនោះ គឺបង្កជាព្យសនកម្មតិចតួចប៉ុណ្ណោះ ដែលមិនបានបង្កជាហានិភ័យខ្ពស់ដល់ជនរងគ្រោះឡើយ។ ហេតុនេះ សូមតុលាការសម្រេចកែប្រែបទចោទប្រកាន់មកចំពោះកូនក្តីខ្លួនពីបទ៖ លួចមានស្ថានទម្ងន់ទោស មកបទ៖ លួច វិញ។

មេធាវីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយរបស់កូនក្តីខ្លួននាពេលសវនាការ យើញថា កូនក្តីខ្លួនបានធ្វើយសារភាពទទួលស្គាល់កំហុស ដោយមិនបានផ្តល់ផលវិបាកដល់តុលាការនោះឡើយ។ ហេតុនេះ សូមតុលាការមេត្តាសម្រេចផ្តល់ស្ថានសម្រាលទោសមកដល់កូនក្តីខ្លួនផង។

សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] សំណាង បាននិយាយសំដីចុងក្រោយថា៖ សំណូមពរសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសផង។

ជនជាប់ចោទឈ្មោះ [redacted] ពន្ធឺ បាននិយាយសំដីចុងក្រោយថា៖ សំណូមពរសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

- ពិតជាករណី លួចមានស្ថានទម្ងន់ទោស (ឆក់យកទូរស័ព្ទដៃ) មួយបានកើតឡើង កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ នៅចំណុចមុខអាផាតមិន H.M.H ផ្លូវលេខ ១៣៥ កែងផ្លូវលេខ ៤៧៨ ស្ថិតនៅភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌ

ចំការមន រាជធានីភ្នំពេញ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សំណាង អាទប្រុស និងឈ្មោះ [redacted] ពន្ធី អាទប្រុស ប្រាកដមែន ដោយហេតុថា នៅថ្ងៃកើតហេតុជនជាប់ចោទទាំងពីររូបនេះ បានជិះម៉ូតូ០១គ្រឿង ម៉ាក ហុងដា ឌ្រីម សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ ពាក់ផ្លាកលេខ ភ្នំពេញ 1FH-5171 ហើយបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃម៉ាក Iphone 6Plus ពណ៌ខ្មៅ ពីជនរងគ្រោះឈ្មោះ [redacted] ស្រីនិច រួចជិះគេចខ្លួន តែត្រូវសមត្ថកិច្ចជិះដេញតាម និងឃាត់ខ្លួនបានតែម្តង។

- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ពន្ធី ឃើញថា បានឆ្លើយសារភាពទទួលស្គាល់អំពីការចោទប្រកាន់ប្រាកដមែន ដែលចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងផ្សេងៗទៀតមាននៅក្នុងសំណុំរឿង ក៏អាចជារបាយការណ៍របស់សមត្ថកិច្ច អាចឱ្យតុលាការជឿថា ជនជាប់ចោទឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ពន្ធី ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (ឆក់យកទូរស័ព្ទដៃ) ប្រាកដមែន។

- តាមកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ៣៨១៩ រ.វ.ត ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃើញថា វត្ថុចាប់យករួមមាន៖

១-ទូរស័ព្ទដៃ ០១គ្រឿង ម៉ាក VIVO ពណ៌ក្រហម (មិនដំណើរការ)។

២-លោហៈធាតុពណ៌លឿង (កងដៃ) ចំនួន ០១ ការ៉ែ។

៣-លោហៈធាតុពណ៌លឿង (ខ្សែ-ក) ចំនួន ០១ខ្សែ ការ៉ែ។

៤-ម៉ូតូ ០១គ្រឿង ម៉ាក DREAM ពណ៌ខ្មៅ អត់កាចាំង ពាក់ផ្លាកលេខ ភ្នំពេញ 1FH-5171 (មិនប្រក្រតី)។

គប្បីតុលាការលើកយកមកពិចារណាតាមច្បាប់។

- នៅក្នុងរឿងនេះ ឈ្មោះ [redacted] ស្រីនិច បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបានឆ្លើយនៅដំណាក់សមត្ថកិច្ច សុំឱ្យចាត់ការជនជាប់ចោទតាមច្បាប់ ប៉ុន្តែមិនបានចូលមកចំពោះមុខតុលាការ ដើម្បីប្តឹងទាមទារសំណងអ្វីនោះឡើយ។ គប្បីតុលាការមិនពិចារណាអំពីសំណងរដ្ឋប្បវេណីទេ។

- ជនជាប់ចោទឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ពន្ធី បាននិយាយសំដីចុងក្រោយប្រហាក់ប្រហែលគ្នាថា៖ សុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួន។ គប្បីតុលាការលើកយកមកពិចារណា។

- មេធាវីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ សូមតុលាការសម្រេចកែប្រែបទចោទប្រកាន់មកចំពោះកូនក្តីខ្លួនពីបទ៖ លួចមានស្ថានទម្ងន់ទោស មកបទ៖ លួច វិញ។

- មេធាវីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ សូមតុលាការមេត្តាសម្រេចផ្តល់ស្ថានសម្រាលទោលមកដល់កូនក្តីខ្លួនផង។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ សុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែល។

- មានពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សំណាង អាទប្រុស ឆ្នាំកំណើត ២៣-០២-២០០៤ និងឈ្មោះ [redacted] ពន្ធី អាទប្រុស ឆ្នាំកំណើត ១៨-០៦-២០០៦ ពីបទ: ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោស (ឆក់យកទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចមុខអាផាតមិន H.M.H ផ្លូវលេខ ១៣៥ កែងផ្លូវលេខ ៤៧៨ ស្ថិតនៅភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- ជនជាប់ចោទ គឺជាអនីតិជន ស្ថិតនៅក្នុងវ័យសិក្សាដែលត្រូវការអប់រំបន្ថែម ដើម្បីជាប្រយោជន៍ដល់សង្គម។ ម្យ៉ាងទៀត ជនជាប់ចោទបានឆ្លើយសារភាពទទួលស្គាល់កំហុស ដោយមិនបានផ្តល់ផលវិបាកដល់តុលាការនោះទេ។ គប្បី

តុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទដោយលើកយកបញ្ញត្តិ មាត្រា ១០៧, មាត្រា ១០៨ និងមាត្រា ១៦០ ចំណុចទី ១ នៃក្រមព្រហ្មទណ្ឌ មកពិចារណា។

<u>ហេតុផ្តន្ទេះសម្រេច</u>

១-ផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖

ក-ឈ្មោះ [redacted]សំណាង ភេទប្រុស ឆ្នាំកំណើត ២៣-០២-២០០៤ (មានសាវតាជាតិដូចខាងលើ)

ខ-ឈ្មោះ [redacted] ពន្ធី ភេទប្រុស ឆ្នាំកំណើត ១៨-០៦-២០០៦ (មានសាវតាជាតិដូចខាងលើ)

ក្នុងម្នាក់ៗ កំណត់រយៈពេល **០១ (មួយ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ ដោយអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ០១ (មួយ) ឆ្នាំ ៦ទោសសល់ពីនេះត្រូវអនុវត្តទោសព្យួរចេម្ចាស់** ពីបទ៖ **លួចមានស្ថានទម្ងន់ទោស (រត់យកទូរស័ព្ទដៃ)** ប្រព្រឹត្តនៅចំណុចមុខអាជ្ញាធរមិន H.M.H ផ្លូវលេខ ១៣៥ តែងផ្លូវលេខ ៤៧៨ ស្ថិតនៅភូមិ១ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ១០៧, មាត្រា ១០៨ និងមាត្រា ១៦០ ចំណុចទី ១ នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុចាប់យករួមមាន៖ ទូរស័ព្ទដៃ ០១គ្រឿង ម៉ាក VIVO ពណ៌ក្រហម (មិនដំណើរការ) , ណោហ:ធាតុពណ៌លឿង (កងដៃ) ចំនួន ០១ ការ៉ឡេ , ណោហ:ធាតុពណ៌លឿង (ខ្សែ-ក) ចំនួន ០១ខ្សែ ការ៉ឡេ , ម៉ូតូ ០១គ្រឿង ម៉ាក DREAM ពណ៌ខ្មៅ អត់ការចាំង ពាក់ផ្លាកលេខ ភ្នំពេញ 1FH-5171 (មិនប្រក្រតី) **ប្រគល់ទៅឱ្យម្ចាស់ដើមវិញ។**

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅ **ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២១** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សំណាង** និងឈ្មោះ [redacted] **ពន្ធី** , កំចាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រីនិច** និងប្រកាសជាអសាធារណៈនៅ **ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២១**។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

ក្រឡាបញ្ជីសវនាការ	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
[redacted]			

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ព្រហស្បតិ៍ ៣ រោច ខែ ស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២១

ចាស់បើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner